## ការចូលរួមចំណែកសាធារណៈជាមួយគណៈកម្មការនាយកផ្នែកសិក្សាធិការ

គណៈកម្មការនាយកផ្នែកសិក្សាធិការនឹងទទួលស្ដាប់សេចក្ដីថ្លែងការណ៍មកពីសាធារណជនផ្ទាល់ និង សេចក្ដីថ្លែងការណ៍ដាក់សម្លេងផ្ញើក្នុងទូរស័ព្ទនៅក្នុងកិច្ចប្រជុំលើកក្រោយ ។ សេចក្ដីថ្លែងការណ៍ដាក់សម្លេងផ្ញើក្នុងទូរស័ព្ទ គឺនឹងចាក់ស្ដាប់ក្នុងកិច្ចប្រជុំ បើសិនជានៅសល់ពេល បន្ទាប់ពីសេចក្ដីថ្លែងការណ៍ពីសាធារណជនបានធ្វើបញ្ចប់ផុតទៅ ។

## ការចូលរួមចំណែកផ្ទាល់នៅក្នុងកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការ

មានការសង្ឃឹមទុកជាមុនថា សមាជិកគណៈកម្មការនាយកនឹងចូលរួមនៅក្នុងកិច្ចប្រជុំផ្ទាល់ ប៉ុន្តែ យោងតាមច្បាប់បញ្ជារ N-25-20(11) មកពីអភិបាល Gavin Newsom ដូចស្របតាមការកែតម្រូវដោយច្បាប់បញ្ជារ N-29-20 គឺសមាជិកគណៈកម្មការនាយកអាចចូលរួមប្រជុំពីចម្ងាយ និង ធ្វើការបោះឆ្នោតផ្ដល់សម្លេងបានតាមរយៈជួបប្រជុំពីចម្ងាយ បើសិនជាពួកគេប្រាថ្នាធ្វើជារបៀបនេះ ។ សាធារណជនអាចបើកមើលកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការបានតាមរយៈផ្សាយបង្ហាញភ្លាមៗនៅក្នុង lbschools.net/youtube ។

ដើម្បីធ្វើស្របតាមបទបញ្ជារពីរដ្ឋ និង នៅតាមតំបន់ ដែលប៉ះពាល់មកលើការជួបជុំគ្នាជាសាធារណៈ គឺសាធារណជនមិនអាចចូលរួមស្ដាប់កិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការនៅក្នុងកន្លែងផ្ទាល់បានទេ លើកលែងតែដូចអ្វីរាយបង្ហាញនៅផ្នែកខាងក្រោម ។

គណៈកម្មការនាយកផ្នែកសិក្សាធិការទទួលស្គាល់អំពីយោបល់មកពីសាធារណជន និង ជម្រុញអោយសាធារណជនដាក់ពាក្យផ្ដាំផ្ញើនៅក្នុងកិច្ចប្រជុំជារៀងរាល់លើក ។ ចំពោះសាធារណជនណា ដែលមានចិត្តចូលរួមធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងកិច្ចប្រជុំផ្ទាល់ គឺអាចដើរចូលមកក្នុងបន្ទប់ម្នាក់ម្ដង និង ឡើងនិយាយដោយប្រើ ម៉ៃក្រូហ៊្វូន នៅពេលបានឮឈ្មោះប្រកាស ។ សាធារណជនទាំងអស់ លើកលែងតែមួយចំនួន ដែលស្ថិតនៅក្រោមការអភ័យទោសពីច្បាប់ ត្រូវតែពាក់គម្របមុខមានជាតិកំណាត់ ដែលគ្របប្រមុះ និង មាត់ និង ត្រូវចាកចេញពីបន្ទប់ប្រជុំភ្លាម បន្ទាប់ពីបានប្រើពេលរបស់ខ្លួននិយាយបញ្ចប់ទៅ ដើម្បីទុកពេលអោយអ្នកផ្សេងទៀតចូលមកធ្វើសេចក្ដីថ្លែងការណ៍ជាបន្ត ។ មានតែបុគ្គលិកចាំបាច់តាមចំនួនកំណត់ប៉ុណ្ណោះ ទើបអាចចូលរួមក្នុងកិច្ចប្រជុំបាន (ត្រូវពាក់គម្របមុខផងដែរ) ។ នៅក្នុងពេលបើកទទួលសេចក្ដីថ្លែងការណ៍ គឺសាធារណជននឹងចូលមកម្នាក់ម្ដង ។ បន្ទប់ប្រជុំនឹងប្រើចម្ងាយ ប្រាំមួយ ហ្វីត ដាច់ពីគ្នាគ្រប់ពេល ។

## សេចក្ដីថ្លែងការណ៍ដាក់សម្លេងផ្ញើក្នុងទូរស័ព្ទ

ពាក្យផ្ដាំផ្ញើ (យោបល់) សាធារណៈតាមរយៈថតសម្លេងក្នុងទូរស័ព្ទ គឺជាកម្មសិទ្ធិសាធារណៈ នៅពេលណាសម្លេងបានទទួលការថតចូលភ្លាម ។ មានចំនួនពេល បី នាទីសម្រាប់បើកទទួលការដាក់ពាក្យផ្ដាំផ្ញើពីសាធារណជន ។ បុគ្គលម្នាក់អាចដាក់ពាក្យផ្ដាំផ្ញើបានតែម្ដងប៉ុណ្ណោះមកលើកិច្ចការត្រូវលើកពិគ្រោះនៅក្នុងកិច្ចប្រជុំ និង ពាក្យផ្ដាំផ្ញើម្ដងមកលើកិច្ចការ ដែលមិនបានរាប់បញ្ចូលនៅក្នុងកិច្ចប្រជុំ ។ សូមចងចាំថា ពាក្យផ្ដាំផ្ញើមកលើកិច្ចការ ដែលមិនបានរាប់បញ្ចូលនៅក្នុងកិច្ចប្រជុំ គឺមិនអាចឆ្លើយជូនបានទេនៅក្នុងពេលកំពុងតែប្រជុំ ។ ប៉ុន្តែ សមាជិកគណៈកម្មការនាយកនឹងយកចិត្តស្ដាប់យ៉ាងដិតដល់មកលើពាក្យផ្ដាំផ្ញើទាំងអស់ ហើយពាក្យផ្ដាំផ្ញើទាំងអស់នោះឯង គឺជារឿយៗ បានទទួលជាចំណែកសម្រាប់រាប់បញ្ចូលជាការពិគ្រោះទៅថ្ងៃមុខនៅក្នុងកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការ នៅពេលមានការរាយបង្ហាញជាត្រឹមត្រូវនៅក្នុងរបៀបវារៈ ។

គណៈកម្មការនាយកផ្នែកសិក្សាធិការនឹងទទួលស្ដាប់មុនគេមកលើបុគ្គល ដែលចូលមកធ្វើសេចក្ដីថ្លែងការណ៍ក្នុងកន្លែងផ្ទាល់ ហើយនឹងព្យាយាមទុកពេលនៅសល់សម្រាប់ទទួលស្ដាប់ពាក្យផ្ដាំផ្ញើតាមរយៈថតសម្លេងក្នុងទូរស័ព្ទ ។ ពាក្យផ្ដាំផ្ញើទាំងអស់នឹងបញ្ជូនផ្ទាល់ទៅកាន់សមាជិកគណៈកម្មការនាយក ។

សូមមេត្តាចងចាំថា ជារឿយៗ គឺមានកុមារបើកមើលកិច្ចប្រជុំធ្វើឡើងដោយគណៈកម្មការនាយកផ្នែកសិក្សាធិការ ។ ដូច្នេះ សូមប្រើពាក្យស្របទៅតាមអាយុរបស់កុមារ ។ ដោយមូលហេតុយើងធ្វើការតម្រូវសុំអោយលើកបង្ហាញថា តើពាក្យផ្ដាំផ្ញើ គឺមាន ឬ មិនមានសម្រាប់រាប់បញ្ចូលទៅក្នុងរបៀបវារៈ ហើយបើពិតដូច្នោះមែន តើមានកិច្ចការណាខ្លះ ដែលត្រូវលើកពិគ្រោះ ... មានតែពាក្យផ្ដាំផ្ញើបានទទួល បន្ទាប់ពី

របៀបវារៈបានបិទតាំងផុតទៅប៉ុណ្ណោះ ទើបនឹងអាចចាក់ស្តាប់បាននៅក្នុងពេលកំពុងតែប្រជុំ ។ ចំពោះសាធារណជន ដែលមានចិត្ត ប្រាថ្នាដាក់ពាក្យផ្តាំផ្ញើតាមរយៈថតសម្លងក្នុងទូរស័ព្ទនៅពេលកំពុងតែប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការ គឺគួរប្រើតាមមធ្យោបាយ ដូចតទៅៈ

អោយទាន់ពេលថ្ងៃត្រង់នៅក្នុងថ្ងៃប្រជុំ គឺសូមប្រើទូរស័ព្ទហៅទៅកាន់លេខ (562) 242-2190 ដើម្បីថតសម្លេងដាក់ពាក្យផ្តាំផ្ញើរបស់អ្នក និង ធ្វើតាមអ្វីដូចបានបញ្ជាក់ប្រាប់ ។ ពាក្យផ្តាំផ្ញើទាំងអស់គួរផ្តើមធ្វើឡើងដោយរាយបង្ហាញពត៌មានដូចតទៅៈ

- ឈ្មោះរបស់អ្នក និង កិច្ចការនៅក្នុងរបៀបវារៈ ដែលអ្នកចង់អោយមានការលើកដោះស្រាយជាមួយ ។
- កិច្ចប្រជុំមួយណា ដែលអ្នកប្រាថ្នាអោយពាក្យផ្តាំផ្ញើរបស់អ្នកទទួលការអានអំពី ។

បើសិនជាការថតសម្លេងរបស់អ្នកគ្មានបង្ហាញនោះទេអំពីកិច្ចការណាមួយយ៉ាងច្បាស់លាស់នៅក្នុងរបៀបវារៈ ដែលអ្នកប្រាថ្នាអោយមាន ការលើកដោះស្រាយជាមួយ គឺវានឹងប្រើចាត់ទុកទៅកាន់ចំណែកនៃកិច្ចការមិនបានរាប់បញ្ចូលនៅក្នុងរបៀបវារៈសម្រាប់កិច្ចប្រជុំសាធារ ណៈ ។

បើសិនជាអ្នកមានបញ្ហា ដែលធ្វើអោយអ្នកគ្មានសមត្ថភាពបង្ហាញអំពីពាក្យផ្តាំផ្ញើរបស់អ្នកបាន ទោះជាតាមរយៈមកចូលរួមក្នុងកន្លែងប្រជុំ ផ្ទាល់ក្តី ឬ តាមរយៈដាក់សម្លេងផ្ញើក្នុងទូរស័ព្ទផ្ទាល់ក្តី គឺសូមអញ្ជើញទាក់ទងទៅកាន់អ្នកស្រី Leticia Rodriguez តាមលេខទូរស័ព្ទ (562) 997-8240 ។